# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាបើកឆ្នាំនៃគ្រួសារនៅភ្នំពេញថ្មី
# ថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨

*គ្រួសារថ្មីដើម្បីពិភពថ្មី*

អត្ថបទទី១៖ កណ ១៥,១-៦.២១,១-៣
ដំណឹងល្អ៖ លក ២,២២-៤០

បងប្អូនជាទីស្រឡាញ់!

"**គ្រួសារថ្មីដើម្បីពិភពថ្មី**" ក្នុងរយៈពេលបីថ្ងៃកន្លងមក ខ្ញុំបានស្តាប់ទុក្ខលំបាក បញ្ហា អំណរសប្បាយ កង្វល់ សេចក្តីសង្ឃឹមរបស់គ្រួសារដែលបានផ្តល់សក្ខីភាព សំណូមពររបស់បងប្អូន ដើម្បីឲ្យព្រះសហគមន៍យកចិត្តទុកដាក់ និងថែរក្សាក្រុមគ្រួសារនីមួយៗ។ ខ្ញុំបានស្តាប់សេចក្តីសង្ឃឹមរបស់បងប្អូន ដើម្បីសាងសង់គ្រួសារដ៏សុខសាន្តគ្រួសារ ដែលពោរពេញដោយសុភមង្គល។ តាមពិតគ្រួសារដ៏សុខសាន្ត គឺជាក្តីសង្ឃឹមរបស់គ្រួសារនីមួយៗ ជាសេចក្តីសង្ឃឹមដើម្បីណែនាំឲ្យគ្រួសារថ្មីបង្កើតពិភពថ្មី។ ខ្ញុំបានស្តាប់បងប្អូនដែលបានចែកបទពិសោធន៍ អំពីការយកចិត្តទុកដាក់ដើម្បីកសាងគ្រួសារដ៏សុខសាន្ត គ្រួសារដែលណែនាំឲ្យកូនៗមានអំណរសប្បាយ មានភាពកក់ក្តៅមានជីវិតដ៏បរិបូរណ៍។ ខ្ញុំបានស្តាប់បងប្អូនដែលថា ដើម្បីបង្កើតគ្រួសារដ៏សុខសាន្ត យើងត្រូវការយល់ចិត្តគ្នា យើងត្រូវការស្តាប់គ្នាទៅវិញទៅមក យើងត្រូវការយល់ចិត្តគ្នាទៅវិញទៅមក យើងត្រូវការលើកលែងទោសឲ្យគ្នាទៅវិញទៅមក។ ខ្ញុំបានស្តាប់បងប្អូនដែលបានផ្តល់សាក្ខីភាព ដើម្បីបង្កើតគ្រួសារដ៏សុខសាន្តយើងត្រូវការជួយគ្នាទៅវិញទៅមក នៅពេលប្តីអស់កម្លាំង នៅពេលប្រពន្ធអស់កម្លាំង ឲ្យយើងចេះលើកទឹកចិត្តនៅក្នុងការជួយគ្នាទៅវិញទៅមក។ ខ្ញុំបានស្តាប់ យើងត្រូវតែយកចិត្តទុកដាក់ ដើម្បីនិយាយសេចក្តីពិតឲ្យគ្នាទៅវិញទៅមក កុំឲ្យយើងកុហក់ពេលយើងធ្វើអ្វីខុស ពេលដែលយើងធ្វើអ្វីមិនត្រឹមត្រូវ ឲ្យយើងហ៊ាននិយាយសេចក្តីពិត។ ខ្ញុំបានស្តាប់ ឲ្យយើងយកចិត្តទុកដាក់ដើម្បីអរគុណគ្នាទៅវិញទៅមក ប្រពន្ធអរគុណប្តី ប្តីអរគុណប្រពន្ធ ឪពុកម្តាយអរគុណកូន ឲ្យកូនចេះអរគុណឪពុកម្តាយ។ ខ្ញុំបានស្តាប់ នៅពេលយើងជាគ្រួសារយើងលែងគិតអំពីរឿងៗខ្លួន ប៉ុន្តែឲ្យយើងគិតគ្នា យើងជាពីរនាក់ យើងជាបួននាក់ យើងជាដប់នាក់ រួមជាមួយកូនៗរបស់យើង។ យើងលែងគិតអំពីផ្ទាល់ខ្លួន អំពីគំនិតអាត្មានិយម។ ប៉ុន្តែ យើងត្រូវការស្តាប់អ្វីដែលប្តីនិយាយ អ្វីដែលប្រពន្ធនិយាយ អ្វីដែលកូននិយាយ ដើម្បីគិតគ្នាដោយពិចារណា។ ខ្ញុំបានស្តាប់ អំណរសប្បាយដែលគ្រួសារនីមួយៗមាន នៅពេលគេអាចជួបយអ្នកដទៃ ចែករំលែកអំណរសប្បាយដែលខ្លួនមានដល់បងប្អូនឯទៀតៗ។ ដោយសារគ្រួសារនីមួយៗ មិនអាចរស់ដោយខ្លួនឯងបានទេ ប៉ុន្តែរស់ដោយបើកចិត្តគំនិត ដោយមើលឃើញគ្រួសារដទៃ និងអំណរសប្បាយរកឃើញនៅពេលយើងជួយគ្រួសារដទៃដែរ។ ខ្ញុំបានស្តាប់គ្រួសារនីមួយៗ ហាក់បីដូចជាព្រះសហគមន៍យ៉ាងតូចមួយ និង

ព្រះសហគមន៍ទៅជាមហាគ្រួសាររបស់យើង។ ពិតមែន! គ្រួសារនីមួយៗជាព្រះសហគមន៍ដ៏តូចមួយ ជាមូលដ្ឋាននៃសង្គមរបស់យើង ជាកោសិកានៃសង្គមផង និងជាកោសិកានៃព្រះសហគមន៍ផង។ ប៉ុន្តែ ណែនាំឲ្យព្រះសហគមន៍របស់យើងទៅជាមហាគ្រួសារមួយ ដែលជួយលើកទឹកចិត្ត ដែលជួយណែនាំឲ្យមានសេចក្ដីសង្ឃឹមជានិច្ច ជាពិសេសនៅពេលយើងកំពុងអស់កម្លាំងលើផ្លូវនៃគ្រួសាររបស់យើងផ្ទាល់ ។

បងប្អូនជាទីស្រឡាញ់! នេះពេលវេលានៅក្នុងបីឆ្នាំខាងមុខ ដើម្បីបើកទ្វារនៃដួងចិត្តរបស់យើងដោយសារព្រះជាម្ចាស់ បានណែនាំឲ្យយើងទទួលកូនសោរមួយ ដើម្បីបើកទ្វារនៃដួងចិត្តរបស់យើង ដើម្បីបើកទ្វារនៃក្រុមគ្រួសាររបស់យើង ឲ្យក្រុមគ្រួសាររបស់យើងរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃ។ នេះជាសំណូមពររបស់ខ្ញុំ នៅក្នុងពេលបីឆ្នាំខាងមុខ **យើងធ្វើយ៉ាងម៉េចដើម្បីឲ្យគ្រួសារនីមួយៗរកឃើញសារជាថ្មីអំពីអំណរសប្បាយនៃក្ដីស្រឡាញ់?** សេចក្ដីស្រឡាញ់ គឺជាអំណរសប្បាយមួយយ៉ាងពិសេស ដែលយើងបានទទួលនៅថ្ងៃដែលយើងធ្វើអគ្គសញ្ញាអាពាហ៍ពិពាហ៍ ជាពេលវេលាមួយពិសេស នៅពេលយើងបានទទួលកូនរបស់យើង។ ជាពេលវេលាមួយយ៉ាងពិសេស នៅពេលកូនរបស់យើងរៀបការ។ ជាពេលវេលាមួយយ៉ាងពិសេស នៅពេលយើងមានកូនចៅហើយ។ ក្រុមគ្រួសារមិនមែនមានតែឪពុកម្ដាយ ក្រុមគ្រួសារមានឪពុកម្ដាយ មានកូន មានលោកតាលោកយាយមានម៉ីង មានពូ មានបងប្អូនទាំងអស់ ដែលនៅក្នុងក្រុមគ្រួសាររបស់យើង ដែលណែនាំឲ្យពីមួយថ្ងៃទៅមួយថ្ងៃ យើងរកឃើញអំណរសប្បាយនៃសេចក្ដីស្រឡាញ់។ អំណរសប្បាយដោយទទួលកូនៗនៅក្នុងក្រុមគ្រួសាររបស់យើង។ នៅពេលយើងជាប្ដីប្រពន្ធ មានខ្លះគេអត់ទាន់ចង់មានកូនភ្លាមៗទេគេថាចាំសិន។ ប៉ុន្តែ កុំចាំទៀតដោយសារមានកូនយើងមានអំណរសប្បាយដ៏ពេញលក្ខណៈ ដោយសារយើងបំពេញគម្រោងការរបស់ព្រះជាម្ចាស់ "សូមមានកូនយ៉ាងច្រើន"។ ដោយសារយើងបំពេញសេចក្ដីស្រឡាញ់ដែលយើងមានរវាងប្ដីនិងប្រពន្ធ ដោយបង្កើតជីវិតថ្មី។ ឪពុកម្ដាយ ចង់មើលកូនមានមុខដូចឪពុក ដូចម្ដាយ ដូចតា ដូចយាយ យើងសប្បាយចិត្តណាស់។

**អំណរសប្បាយដោយសារយើងជាក្រុមគ្រួសារចេះជួបជុំគ្នា** សម្រាប់បីឆ្នាំខាងមុខតាមព្រះសហគមន៍នីមួយៗ យើងមានបាណ្ឌ ដែលជាអំណរសប្បាយនៃគ្រួសារដែលជួបជុំគ្នាម្ដងៗ យើងមិនអាចជួបជុំគ្នារួមគ្រប់ពេលវេលា។ សម្រាប់យើងម្ដងៗ ពេលបុណ្យភ្ជុំបិណ្ឌ ពេលបុណ្យចូលឆ្នាំពេលបុណ្យព្រះយេស៊ូប្រសូត ឲ្យយើងបង្ហាញប្រពៃណីនៅពេលបុណ្យព្រះយេស៊ូប្រសូតដែរ។ ឲ្យយើងជួបជុំគ្នាជាលក្ខណៈគ្រួសារ ដើម្បីចែករំលែកអំណរសប្បាយ ដើម្បីសួរសុខទុក្ខគ្នាទៅវិញទៅមក ដើម្បីណែនាំឲ្យលោកតាលោកយាយមានកម្លាំង ដោយសារឃើញកូនចៅ ដើម្បីឲ្យកូនចៅស្តាប់លោកតាលោកយាយនិទានរឿងនិទានយ៉ាងច្រើន ដើម្បីឲ្យនិយាយអំពីការបង្កើតប្រពៃណីយ៉ាង

ច្បាស់។ យប់មិញយើងបានមើលរឿង មានលោកតាដែលប្រមូលកូនចៅ និងកូនចៅគេបានសួរអំពីកំណើតពិភពលោក។ ដូច្នេះទុកឲ្យកូនចៅទៅសួរលោកតា លោកយាយ អំពីប្រទេសកម្ពុជាពីដើម? អំពីប្រពៃណីយើងពីដើម? អំពីជីវិតនៅស្រុកស្រែពីដើម? អំពីសេចក្តីសុខសាន្តនៅក្នុងក្រុមគ្រួសារពីដើម? នេះយើងស្តាប់លោកតាគាត់និយាយប្រាប់ យើងស្តាប់អ្វីដែលកើតឡើងពីដើមដើម្បីមានអំណរសប្បាយនៅពេលក្រុមគ្រួសារជួបជុំគ្នា។ សព្វថ្ងៃមានគ្រួសារខ្លះគេឈ្លោះគ្នា គេបាក់បែកគ្នាដោយសារទូរស័ព្ទ គេលួចមើលខ្លាចប្រពន្ធមានទំនាក់ទំនងជាមួយប្រុសផ្សេងៗ ប្តីមានទំនាក់ទំនងជាមួយស្រីផ្សេងតាមទូរស័ព្ទ។

ខ្ញុំជឿថាយើងមានកូនសោរខ្លះៗ ដើម្បីបើកទ្វារនៃដួងចិត្តរបស់យើង ហើយណែនាំឲ្យក្រុមគ្រួសាររបស់យើងរកឃើញសេចក្តីសុខសាន្តនៅខាងមុខ៖

**កូនសោរទីមួយ គឺការលើកលែងទោស!** នៅពេលយើងមានបញ្ហាអ្វីមួយយើងនិយាយសេចក្តីពិត យើងឈ្លោះគ្នាមួយភ្លែត ប៉ុន្តែដើម្បីទៅដល់ការលើកលែងទោសដែលនាំឲ្យផ្សះផ្សារគ្នាវិញ ដើម្បីធ្វើដំណើរបន្តជាមួយគ្នា និងដើម្បីណែនាំឲ្យកូនៗរបស់យើងមានសេចក្តីសុខសាន្ត។ យើងបានស្តាប់ នៅពេលកូនៗឃើញឪពុកម្តាយត្រូវគ្នា កូនមានកម្លាំងណាស់។ នៅពេលកូនៗឃើញឪពុកម្តាយចេះតែឈ្លោះគ្នា ណែនាំឲ្យកូនៗពិបាកចិត្តដែរ។ ទោះបីកូនតូចក៏ដោយ! កុំគិតថាយើងអត់មានឥទ្ធិពលលើកូនតូច គេមើលទាំងអស់ គេទទួលទាំងអស់ គេស្តាប់ទាំងអស់ ហើយណែនាំឲ្យគេទទួលរបួសនៅក្នុងចិត្ត ដោយសារគេចង់ឲ្យឪពុកម្តាយស្រឡាញ់គ្នា។

**កូនសោរទីពីរ គឺជំនឿ!** យើងបានស្តាប់សាក្សីភាពកន្លងមក ដោយសារជំនឿរបស់យើង យើងសូមឲ្យព្រះជាម្ចាស់ផ្តល់កម្លាំងថ្មី។ ដោសារជំនឿរបស់យើង យើងអធិដ្ឋានជាលក្ខណៈគ្រួសារដើម្បីទទួលជីវិតថ្មី។

**កូនសោរទីបី គឺសេចក្តីសង្ឃឹម!** យើងបានស្តាប់មានគ្រួសារមួយដែលបែកបាក់គ្នា៨ឆ្នាំ ប៉ុន្តែមកជួបជុំគ្នាវិញ ហើយធ្វើដំណើរជាមួយគ្នាសារជាថ្មី ដោយថែរក្សាសេចក្តីសង្ឃឹមជានិច្ច។

**កូនសោរទីបួន គឺការតស៊ូ!** ដោយសារបើគ្មានការតស៊ូ ឈ្លោះគ្នាមួយភ្លែតបាក់បែកគ្នាមួយភ្លែត។ ជីវិត មិនមែនជាស្ទឹងមួយដែលស្ងៀមស្ងាត់ មិនមែនជាទន្លេមួយដែលស្ងៀមស្ងាត់ ជួនកាលទឹកច្រើន ជួនកាលមានខ្យល់ ជួនកាលវាស្ងៀមស្ងាត់ដែរ។ ដូច្នេះជីវិតយើងជាគ្រួសារ មិនមែនជាទន្លេដែលស្ងៀមស្ងាត់ ប៉ុន្តែជាទន្លេដែលមានទឹកជំនន់ផង ភាពភាពរាំងស្ងួតផង មានរលកផង ស្ងៀមស្ងាត់ផង។

បងប្អូនជាទីស្រឡាញ់! យើងបើកទ្វារនៃដួងចិត្តរបស់យើង ដោយប្រើកូនសោរដែលយើងមាន គឺការលើកលែងទោស ជំនឿ សេចក្តីសង្ឃឹម និងការតស៊ូយើងមើលគ្រួសារដ៏វិសុទ្ធ ដែលកំពុងបំភ្លឺយើង ដែលកំពុងទន្ទឹងរង់ចាំយើង យើងមើលឃើញព្រះពន្លឺគឺព្រះយេស៊ូផ្ទាល់។ កុំភ្លេច ដើម្បីមើលព្រះពន្លឺ យើងត្រូវការចេញធ្វើដំណើរសិន! ប្រសិនបើយើងបិទទ្វារចាក់សោរ ប្រសិនបើយើងរស់នៅក្នុងមន្ទីរឃុំឃាំងនៃដួងចិត្តរបស់យើង យើងមើលពន្លឺមិនឃើញទេ។ ដូចហោរាចារ្យចេញធ្វើដំណើរ ហេតុដូច្នេះហើយគេបានមើលឃើញផ្កាយ។ សម្រាប់យើងក៏ដូចគ្នាដែរ ដើម្បីមើលព្រះពន្លឺរបស់ព្រះយេស៊ូឲ្យយើងបើកទ្វារបន្តិចម្តងៗ ដើម្បីមើលគ្រួសារដ៏វិសុទ្ធ ដែលកំពុងញញឹមដាក់យើង ដែលកំពុងផ្តល់សេចក្តីស្រឡាញ់ដល់យើង ដែលមានភ្នែកដ៏ត្រចះត្រចង់ដើម្បីណែនាំឲ្យយើងពោរពេញដោយរស្មីរបស់ព្រះជាម្ចាស់។

សូមព្រះជាម្ចាស់ ប្រទានពរដល់គ្រួសារយើងទាំងអស់ ដើម្បីឲ្យគ្រួសារនីមួយៗទៅជាគ្រួសារដ៏វិសុទ្ធដ៏តូចមួយ ដើម្បីឲ្យគ្រួសារនីមួយៗទៅជាគ្រួសារដ៏សក្ការៈដ៏តូចមួយ ដើម្បីឲ្យគ្រួសារនីមួយៗទៅជាពន្លឺដ៏តូចមួយ សម្រាប់គ្រួសារដែលកំពុងពិបាក ដែលកំពុងអស់សង្ឃឹម។

យើងអរព្រះគុណព្រះជាម្ចាស់ និងសូមព្រះអង្គគង់នៅជាមួយយើង ដើម្បីឲ្យឆ្នាំនៃគ្រួសារទៅជាកម្លាំងថ្មីសម្រាប់ព្រះសហគមន៍កម្ពុជារបស់យើង ដើម្បីឲ្យឆ្នាំនៃគ្រួសារទៅជាកម្លាំងមួយយ៉ាងពិសេស សម្រាប់គ្រួសារនីមួយៗ ពិតមែនជាគ្រួសារថ្មីដើម្បីពិភពថ្មី។ អាម៉ែន៕